# ពាណិជ្ជកម្មកសិកម្មនៅមហាអនុតំបន់មេគង្គៈ ការប្រមើលមើលពីការអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា

*បណ្ឌិត ធន់ វឌ្ឍនា បណ្ឌិត សុខ ស៊ីណា និងលោកស្រី ឆាយ ពិដោរ ពិភាក្សាពីស្ថានភាពបច្ចុប្បន្ននៃពាណិជ្ជកម្មក្នុងតំបន់លើទំនិញកសិកម្ម និងចំណងទាក់ទងជាមួយការអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា និងពិនិត្យពីការវិវត្តន៍ទៅអនាគតនៃពាណិជ្ជកម្មកសិកម្មក្នុងតំបន់ និងផ្ដល់អនុសាសន៍ខាងគោលនយោបាយសំដៅជំរុញពាណិជ្ជកម្មកសិកម្មនៅ* GMS ។*

## ប្រវត្តិខាងសេដ្ឋកិច្ច-សង្គមកិច្ចនៃបណ្ដាប្រទេស GMS

មហាអនុតំបន់មេគង្គ (GMS) មានផ្ទៃក្រឡាសរុបប្រហែល ២,៣លានគ.ម$^{២}$ ប្រជាជន ២៦២លាននាក់ និងប្រទេសសមាជិកចំនួន ៦ គឺ កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម និង ខេត្តយូណាន់ នៃប្រទេសចិន ។ បណ្ដាប្រទេសសមាជិកមានទន្លេរួមគ្នាមួយគឺ ទន្លេមេគង្គ ដែលមានប្រវែង ៤.២០០គ.ម និងជាទន្លេវែងជាងគេក្នុងលំដាប់ទីដប់ នៅលើពិភពលោក ។ GMS សំបូរធនធានធម្មជាតិ មានរ៉ែច្រើនមុខ មានសក្ដានុពលខាងវារីអគ្គិសនី ធនធានត្រី និងដីជីជាតិល្អ ។

ចំណែកនៃកសិកម្មនៅក្នុងសេដ្ឋកិច្ចមានពី ១១% នៅថៃ រហូតដល់ជិត ៥០% នៅមីយ៉ាន់ម៉ា (តារាង១) ។ ថ្វីបើកសិកម្មនៅមានចំណែកធំក្នុងផសស ប៉ុន្តែប្រទេសនីមួយៗបានប្រឹងប្រែងកែប្រែរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួន ទៅខាងឧស្សាហកម្ម និងសេវាកម្មវិញ ។ លើកលែងតែប្រទេសថៃដែលមានសេដ្ឋកិច្ចទីផ្សារជាច្រើនទសវត្សរ៍មកហើយ ប្រទេស GMS ទាំង ៥ទៀត សុទ្ធតែជាអតីតសេដ្ឋកិច្ចមានផែនការប្រមូលផ្ដុំ និងមានមធ្យោបាយផលិតកម្មជារបស់រដ្ឋ ហើយសព្វថ្ងៃកំពុងធ្វើអន្តរកាលទៅកាន់សេដ្ឋកិច្ចទីផ្សារ និងបើកចំហសេដ្ឋកិច្ចឱ្យបរទេសមកបណ្ដាក់ទុន ។ ប៉ុន្តែនៅ មីយ៉ាន់ម៉ា ដំណើរការនេះយឺតយ៉ាវ ដោយសារហេតុផលខាងនយោបាយ ។

ដោយមានកំលាំងពលកម្មច្រើន និងប្រាក់ចំណូលក្នុងមនុស្សម្នាក់កំពុងកើនឡើង បណ្ដាប្រទេស GMS មានមូលដ្ឋានផលិតកម្មមានលក្ខណៈទាក់ទាញល្អ និងជាទីផ្សារសក្ដានុពល ។ ក្រុមហ៊ុននានានៅអាស៊ីខាងកើត កំពុងផ្ទេរកាន់តែច្រើនឡើងនូវផលិតកម្មប្រើពលកម្មច្រើន មកដំណើរការនៅក្នុង GMS វិញ ដើម្បីអាចប្រើប្រាស់កំរិតបៀវត្សរ៍មានលក្ខណៈប្រកួតប្រជែង នឹងកំលាំងពលកម្មដែលនៅសល់ច្រើន និងកាន់តែមានជំនាញខ្ពស់ ។

ពាណិជ្ជកម្មអន្តរជាតិនៃ GMS ទាំងមូល មានឱនភាពបន្តិច ប៉ុន្តែសំរាប់ប្រទេសមិនមែនឥណ្ឌូចិនទាំងបី គឺមានអតិរេក ។ បណ្ដាប្រទេស GMS នាំចេញផលិតផលជាច្រើនមុខ ប៉ុន្តែភាគច្រើនស្ថិតក្នុង ២-៣ ប្រភេទប៉ុណ្ណោះ ។ វាយនភ័ណ្ឌគឺជាទំនិញនាំចេញឃើញមានជាទូទៅនៅឥណ្ឌូចិន ហើយចំណែកភាគរយនៅក្នុងការនាំចេញសរុបមានតាំងពី ១៣,៣% នៅវៀតណាម រហូតដល់ ៧៦,៩% នៅកម្ពុជា ។ ដើម្បីបង្កើនពាណិជ្ជកម្ម បណ្ដាប្រទេស GMS បានប្ដេជ្ញាបើកចំហសេដ្ឋកិច្ច និងធ្វើកំណែទំរង់រចនាសម្ព័ន្ធស្របតាមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) និង កម្មវិធីប្រមូលផលដើមដៃ ។ លើកលែងតែមីយ៉ាន់ម៉ា និង ឡាវ ចេញ ប្រទេស GMS ទាំងអស់សុទ្ធតែជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

អត្ថបទនេះ ពិភាក្សាវែកញែកពីស្ថានភាពបច្ចុប្បន្ននៃពាណិជ្ជកម្មក្នុងតំបន់លើទំនិញកសិកម្ម និងចំណងទាក់ទងជាមួយការអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា ។ អត្ថបទ ក៏ពិនិត្យពីការវិវត្តន៍ទៅអនាគតនៃពាណិជ្ជកម្មកសិកម្មក្នុងតំបន់ និងផ្ដល់អនុសាសន៍ខាងគោលនយោបាយ សំដៅជំរុញពាណិជ្ជកម្មកសិកម្មនៅតំបន់ GMS ។ ការសិក្សានេះផ្ដោតលើប្រទេសកម្ពុជាតែមួយ រីឯព័ត៌មានស្ដីពីប្រទេស GMS ឯទៀត គឺសំរាប់ប្រៀបធៀបគ្នាតែប៉ុណ្ណោះ ។

## ពាណិជ្ជកម្ម និងការអភិវឌ្ឍន៍

*ប្រវត្តិសង្ខេប*

តួនាទីពាណិជ្ជកម្មអន្តរជាតិក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច បានទទួលការយកចិត្តទុកដាក់ពីសេដ្ឋវិទូ អ្នកកសាងគោលនយោបាយ អ្នកនយោបាយ និងក្រុមហ៊ុនអន្តរជាតិធំៗ ជាច្រើនសតវត្សរ៍មកហើយ ។ ថ្វីបើពាណិជ្ជកម្មនេះ បានកើតមានជាច្រើនរយឆ្នាំ ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធរបស់វានៅតែអន់ខ្សោយ ក្នុងមួយភាគធំនៃរយៈពេលនោះ ។ ទីផ្សាររូបិយវត្ថុ ទីផ្សារទំនិញ និងទីផ្សារឥណទាន បានរីកលូតលាស់ដើម្បីជួយសំរួលពាណិជ្ជកម្ម និងការពង្រីកទឹកដីអាណានិគម ក្នុងសតវត្សរ៍ទី១៦ និង ១៧ ។ នៅពេលនោះ ទ្រឹស្ដីសេដ្ឋកិច្ចដែលគេហៅថា ពាណិជ្ជកម្មនិយម បានជំរុញការនាំចេញ ប៉ុន្តែបន្ថយបង្អាក់ការនាំចូល ។ ដូច្នេះហើយក៏មានគោលនយោបាយពាណិជ្ជកម្មរឹតត្បិតច្រើនបែបច្រើនយ៉ាង ដូចជា ពន្ធនាំចូល អាជ្ញាប័ណ្ណ និង ឧបត្ថម្ភធនសំរាប់ការនាំចេញ ជាដើម ។

ក្នុងសម័យបដិវត្តន៍ឧស្សាហកម្មនៅចុងសតវត្សរ៍ទី១៨ គោលគំនិតបែបពាណិជ្ជកម្មនិយម កាន់តែមានគេជំទាស់ច្រើន ពីព្រោះវត្ថុធាតុដើមសំរាប់បង្កើនទំនិញនាំចេញ មិនអាចផ្គត់ផ្គង់គ្រប់គ្រាន់ ដោយផលិតកម្មក្នុងស្រុកបានទេ ដូច្នេះសាមីប្រទេសត្រូវតែបន្ធូរបន្ថយគោលនយោបាយពាណិជ្ជកម្មលើការនាំចូលវត្ថុធាតុដើម ។ នៅដើមសតវត្សរ៍ទី១៩ ចលនាធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចដ៏ខ្លាំងក្លាមួយបានកកើតឡើង តាមរយៈការលុបបំបាត់ជាឯកតោភាគីនូវកំហិតផ្សេងៗលើពាណិជ្ជកម្មនៅក្នុង ចក្រភពអង់គ្លេស (មហាអំណាចសេដ្ឋកិច្ចនាពេលនោះ) ដោយចាប់ផ្ដើមតាមការលុបច្បាប់ដំណាំពោត (Corn Law) នៅឆ្នាំ១៨៤៦ ដែលបានបញ្ចប់កម្មវិធីទ្រទ្រង់ថ្លៃផលិតផលកសិកម្មដ៏ធំលើកទី១ ក្នុងពិភពលោក ។ បន្ទាប់មកអង់គ្លេសក៏ព្យាយាមធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មពិភពលោក ដោយទទួលបានជោគជ័យមួយចំនួន ។ ពាណិជ្ជកម្មពិភពលោក មានលក្ខណៈសេរីគួរសមរហូតដល់សង្គ្រាមលោកលើកទី១ ដោយមានគោលនយោបាយការពារផលិតផលក្នុងស្រុក តែលើមុខសញ្ញាខ្លះៗប៉ុណ្ណោះ (Norton and Alwang 1993) ។ ការរីកលូតលាស់ក្នុងការដឹកជញ្ជូន និងទូរគមនាគមន៍ ក៏បានជួយជំរុញដល់ពាណិជ្ជកម្មមួយកំរិតទៀត ។

សកម្មភាពអាជីវកម្មនានារួមទាំងកសិកម្មផង ដែលរីកដុះដាលក្នុងពេលសង្គ្រាម បានជួបឧបសគ្គនៃការធ្លាក់ចុះតំរូវការ និងថ្លៃទំនិញ ក្រោយចប់

* បណ្ឌិត ធន់ វឌ្ឍនា ជាប្រធានស្រាវជ្រាវផ្នែកកសិកម្ម អភិវឌ្ឍន៍ជនបទ និងភាពក្រីក្រ បណ្ឌិត សុខ ស៊ីណា ជាអ្នកស្រាវជ្រាវ និងលោកស្រី ឆាយ ពិដោរ ជាជំនួយការស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ។

**តារាង១ : ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចនៃបណ្តាប្រទេស GMS**

| | កម្ពុជា | ឡាវ | មីយ៉ាន់ម៉ា | ថៃ | វៀតណាម | យូណាន់ | GMS |
|---|---|---|---|---|---|---|---|
| | **2006** | **2006** | **2006** | **2006** | **2006** | **2005** | **2005/6** |
| ផ្ទៃ (000 គម²) | 181.04 | 236.80 | 678.50 | 514.00 | 329.56 | 394.10 | 2334.00 |
| ប្រជាជន (លាននាក់) | 14.10 | 6.52 | 47.37 | 65.23 | 84.16 | 44.50 | 261.89 |
| ផសស/ម្នាក់ (ដុល្លារ) | 419.00 | 425.18 | 202.64 | 3161.85 | 723.45 | 982.00 | 1251.85 |
| ផសស (លានដុល្លារ) | 5931.00 | 2773.00 | 9600.00 | 206,259.24 | 60,883.56 | 42,395.20 | 327,842.00 |
| កសិកម្ម (%) | 28.10 | 43.40 | 50.00 | 10.70 | 20.40 | 18.90 | 15.30 |
| ឧស្សាហកម្ម (%) | 28.70 | 30.60 | 15.00 | 44.60 | 41.50 | 41.76 | 42.38 |
| សេវាកម្ម (%) | 43.20 | 26.00 | 35.00 | 44.70 | 38.10 | 39.34 | 42.31 |
| នាំចេញ (លានដុល្លារ) | 3693.00 | 982.20 | 3560.00 | 130,583.42 | 39,826.00 | 2641.58 | 181,286.20 |
| នាំចូល (លានដុល្លារ) | 4749.00 | 1376.00 | 1980.00 | 128,606.12 | 44,891.00 | 2096.64 | 183,698.77 |

ប្រភព: ចងក្រង និងគណនាដោយអ្នកនិពន្ធ ដោយផ្អែកលើប្រភពជាច្រើន ២០០៧

សង្គ្រាម ។ ក្នុងទសវត្សរ៍១៩២០ និង ១៩៣០ រដ្ឋាភិបាលនានា បានព្យាយាមការពារអាជីវកម្មទាំងនេះ ដោយដាក់អនុវត្តគោលនយោបាយការពារផលិតផលក្នុងស្រុក ដែលពិភពលោកបានតស៊ូរហូតមកដល់សព្វថ្ងៃនេះ ដើម្បីលុបបំបាត់វាចេញវិញ ។ កិច្ចការពារផលិតផលក្នុងស្រុក អាចបង្កើតបន្ទុកចំណាយយ៉ាងច្រើន ធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍន៍មានការព្រួយបារម្ភ ពីព្រោះគេត្រូវបង្កើនការនាំចេញ ដើម្បីទទួលបានរូបិយប័ណ្ណសំរាប់សងបំណុល (Riddel et al. 2002) ។ គោលនយោបាយការពារផលិតផលក្នុងស្រុកមិនចេះចប់ អាចមើលឃើញយ៉ាងច្បាស់ក្នុងការបរាជ័យនៃកិច្ចចរចានៅអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ប្រទេសនីមួយៗអះអាងថា ផលិតផលបរទេសបានប្រកួតប្រជែងដោយអយុត្តិធម៌ ហើយថាផលិតផលរបស់គេផ្ទាល់វាសំខាន់បំផុតសំរាប់សេដ្ឋកិច្ចក្នុងស្រុក និងសុខមាលភាពកសិករ ។ ដូច្នេះ រដ្ឋាភិបាលក្នុងឋានៈជាអ្នកការពារផលប្រយោជន៍សាធារណៈ ត្រូវតែផ្តល់កិច្ចគាំពារទល់នឹងទំនិញនាំចូល ទោះបីជាខ្លួនអះអាងថា គាំទ្រពាណិជ្ជកម្មសេរីក៏ដោយ ។

*ផលប៉ះពាល់នៃពាណិជ្ជកម្ម*

ទាំងក្នុងប្រព័ន្ធផ្សព្វផ្សាយ និងមជ្ឈដ្ឋានអ្នកស្រាវជ្រាវ ពុំមានមតិឯកភាពគ្នាទេពីផលប៉ះពាល់នៃពាណិជ្ជកម្មសេរី ។ ជារឿយៗ ការពិភាក្សាពីពាណិជ្ជកម្មនាំឱ្យមានជំហរពីរផ្ទុយគ្នាគឺ ទី១-ទំនិញនាំចេញនានាជាពិសេសមកពីប្រទេសមានកំរិតអភិវឌ្ឍន៍ខ្ពស់ជាង វាបង្កបញ្ហាដល់ប្រទេសកំពុងអភិវឌ្ឍន៍ និង ទី២-ពាណិជ្ជកម្មបើកចំហវាចាំបាច់ណាស់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ អ្នកគាំទ្រមតិអវិជ្ជមានលើពាណិជ្ជកម្មរែកញែកថា នៅពេលប្រទេសកំពុងអភិវឌ្ឍន៍បានធ្វើសមាហរណកម្មកាន់តែច្រើនទៅក្នុងសេដ្ឋកិច្ចពិភពលោក ពួកគេបើកចំហឱ្យមានការធ្វើអាជីវកម្ម កាន់តែច្រើននៅក្នុងប្រទេសខ្លួនពីសំណាក់ប្រទេសមានកំរិតអភិវឌ្ឍន៍ខ្ពស់ជាង និងពីអ្នកឋានៈខ្ពស់ស្តុកស្តម្ភធនធាន ។ អ្នកគាំទ្រមតិវិជ្ជមានលើពាណិជ្ជកម្មរែកញែកថា វាជួយសំរួលដល់ការអភិវឌ្ឍន៍ ពីព្រោះវានាំឱ្យមានការប្រើប្រាស់ធនធាននានាកាន់តែមានប្រសិទ្ធភាពខ្ពស់ ។ ប្រទេសជាតិអាចបានផលចំណេញ បើសិនគេនាំចេញទំនិញដែលគេអាចផលិតបានថោកជាងប្រទេសឯទៀត និងនាំចូលទំនិញណាដែលប្រទេសឯទៀតផលិតបានថោកជាង ។ អ្នកស្រាវជ្រាវមួយចំនួនរែកញែកថា ពាណិជ្ជកម្មសេរីនឹងផ្តល់ការរីកចំរើនដល់ទាំងប្រទេសនាំចូល និងប្រទេសនាំចេញ បើសិនប្រទេសទាំងពីរមានកំរិតអភិវឌ្ឍន៍សេដ្ឋកិច្ចស្មើគ្នា បើពុំនោះទេនឹងមានអ្នកឈ្នះ និងអ្នកចាញ់ ។ អ្នកចាញ់ភាគច្រើនជាប្រទេសនាំចូលដែលមានប្រសិទ្ធភាពទាបជាង និងសមត្ថភាពប្រកួតប្រជែងខ្សោយជាង ។ អ្នកឈ្នះ គឺជាប្រទេសនាំចេញដែលមានវិធីផលិតមានប្រសិទ្ធភាពខ្ពស់ ។

គំរូបែបបុរាណនៃពាណិជ្ជកម្មសេរីដែលផ្អែកលើការសន្មតថា មានប្រាក់ចំណូលទៀងទាត់ និងមានការប្រកួតប្រជែងល្អឥតខ្ចោះ វាលែងសូវសំខាន់ដូចកាលពីមុនទៀតហើយ ពីព្រោះមានករណីជាក់ស្តែងជាច្រើនបង្ហាញថាសព្វថ្ងៃ គឺប្រាក់ចំណូលកើនឡើងជាលំដាប់ (សេដ្ឋកិច្ចមាត្រដ្ឋាន) និងការប្រកួតប្រជែងមិនល្អឥតខ្ចោះ ដែលជាកត្តានាំឱ្យមានចរាចរទំនិញយ៉ាងច្រើននាពេលបច្ចុប្បន្ន ។ Paul Krugman (2003) អ្នកបង្កើតទ្រឹស្តីពាណិជ្ជកម្មថ្មី និងអ្នកស្រាវជ្រាវជាច្រើនទៀតបានអះអាងថា ពាណិជ្ជកម្មមិនមែនសុទ្ធតែជាលទ្ធផលនៃឧត្តមភាពប្រៀបធៀបនោះទេ ។ ផ្ទុយទៅវិញ វាអាចជាលទ្ធផលនៃប្រាក់ចំណូលកើនឡើងជាលំដាប់ ឬសេដ្ឋកិច្ចមាត្រដ្ឋាន ពោលគឺនិន្នាការថយចុះតំលៃឯកតា នៅពេលគេផលិតកាន់តែច្រើនឡើង ។

សេដ្ឋកិច្ចមាត្រដ្ឋាន បានជំរុញឱ្យប្រទេសនានាធ្វើឯកទេសនីយកម្មលើផលិតកម្ម និងពាណិជ្ជកម្ម ទោះបីធនធាន ឬបច្ចេកវិទ្យារបស់ខ្លួន គ្មានអ្វីខុសប្លែកពីគេក្តី ។ ក្នុងការពិតជាក់ស្តែង សេដ្ឋកិច្ចមាត្រដ្ឋានច្រើនជាលទ្ធផលនៃការប្រកួតប្រជែងមិនល្អឥតខ្ចោះ ជាជាងការប្រកួតប្រជែងល្អឥតខ្ចោះ ។ រដ្ឋាភិបាល មានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតសេដ្ឋកិច្ចមាត្រដ្ឋានតាមរយៈការគាំទ្រដល់ការស្រាវជ្រាវ និងអភិវឌ្ឍន៍របស់ក្រុមហ៊ុនក្នុងស្រុក ។ យោងតាមទ្រឹស្តីពាណិជ្ជកម្មថ្មី និងទ្រឹស្តីកំណើនថ្មី ចំណាយច្រើនៗសំរាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ គឺជាប្រភពដ៏រឹងមាំនៃលទ្ធផលសេដ្ឋកិច្ចជាដុំកំភួន (ឥទ្ធិពលខាងក្រៅ) ។ នៅក្នុងស្ថានភាពខ្លះ សេដ្ឋកិច្ចមាត្រដ្ឋាន គឺជាលទ្ធផលនៃគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្ម ដែលរដ្ឋាភិបាលដាក់អនុវត្តដើម្បីគាំទ្រដល់ក្រុមហ៊ុនក្នុងការប្រកួតប្រជែងជាអន្តរជាតិ ។ ឧបត្ថម្ភធនសំរាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការលក់បង្ខូចថ្លៃ និងពន្ធគយ គឺជាវិធានការ ដែលមានប្រើយ៉ាងច្រើននៅក្នុងគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្មសព្វថ្ងៃ ។

ពាណិជ្ជកម្មនឹងមិនកើតមានឡើងទេ បើសិនថ្លៃដឹកជញ្ជូនវាខ្ពស់ជាងគំលាតរវាងតំលៃឯកតារបស់ប្រទេសនីមួយៗ ។ តំលៃដឹកជញ្ជូនបង្កឧបសគ្គចំពោះពាណិជ្ជកម្ម និងច្រើនជះឥទ្ធិពលទៅលើទំហំ និងទីតាំងនៃក្រុមហ៊ុន ។ នៅក្នុងគំរូតំបន់កណ្ដាល-ជាយ (centre-periphery model) លោក Krugman (1991) បានសន្និដ្ឋានថា តំលៃដឹកជញ្ជូនខ្ពស់នឹងបង្ខំឱ្យផលិតករជ្រើសរើសទីតាំងផលិតកម្មនៅជិតទីផ្សារ ដែលនាំឱ្យកើតមានមជ្ឈមណ្ឌលផលិតកម្មប្រមូលផ្ដុំធំៗ ហើយរឿងនេះនឹងនាំឱ្យមានកំណើនប្រាក់ចំណូលកើនឡើងជាលំដាប់ ។ តំលៃដឹកជញ្ជូនខ្ពស់ នឹងធ្វើឱ្យពាណិជ្ជកម្មឈប់ដំណើរការ និងកាត់ផ្ដាច់ទំនាក់ទំនងរវាងតំបន់កណ្ដាល និងតំបន់ជាយ ។ តំលៃដឹកជញ្ជូនទាប វាជួយសំរួលពាណិជ្ជកម្ម និងផ្ដល់ផលប្រយោជន៏ដល់ប្រទេសអ្នកធ្វើពាណិជ្ជកម្ម ។ ដូច្នេះ វិបុលភាពនឹងកើនឡើងតាមការកាត់បន្ថយតំលៃដឹកជញ្ជូន ។

ពាណិជ្ជកម្មដែលមានការប្រកួតប្រជែងមិនល្អឥតខ្ចោះ គឺជាមូលហេតុនៃទំនាស់ភាគច្រើនខាងពាណិជ្ជកម្ម ។ ក្នុងនេះ ពាណិជ្ជកម្មផលិតផលកសិកម្មនៅតែជាឧបសគ្គធំបំផុតសំរាប់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅក្នុង WTO និង AFTA ទោះបីការរួមចំណែកខាងសេដ្ឋកិច្ចនៃកសិកម្មនៅក្នុងផសស នៅជុំវិញពិភពលោក បានថយចុះយ៉ាងខ្លាំងក្នុងពីរ-បីទសវត្សរ៍ចុងក្រោយក្ដី ។ ក្នុងប្រទេសអភិវឌ្ឍន៏ កសិកម្មមានចំណែកតែ ១.៨% ក្នុងផសស ប៉ុន្ដែវិស័យនេះនៅតែមានច្បាប់ការពារផលិតផលក្នុងស្រុកច្រើនជាងគេ (Martin and Anderson 2006:3) ។ ផ្នែកនេះពិភាក្សាពីផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើការអភិវឌ្ឍន៏ប្រទេសជាប់ទាក់ទិន ។ ផ្នែកជាបន្ទាប់ផ្ដោតលើឥទ្ធិពលគោលនយោបាយពាណិជ្ជកម្មនៅក្នុង GMS និងពិភាក្សាពីមូលហេតុដែល GMS ត្រូវខិតខំជំរុញពាណិជ្ជកម្មក្នុងតំបន់ ។

## ជួញជិត រឺ ជួញឆ្ងាយ?

### *គោលនយោបាយពាណិជ្ជកម្មនៅ GMS*

ដូចបានលើកឡើងនៅខាងលើ កសិកម្មមានតួនាទីយ៉ាងសំខាន់សំរាប់សេដ្ឋកិច្ច និងសង្គមនៃបណ្ដាប្រទេស GMS ដែលមានតំរូវការបង្កើនកសិកម្មដើម្បីកាត់បន្ថយភាពក្រីក្រនៅជនបទ ដូចបានព្រមព្រៀងនៅក្នុងកិច្ចប្រជុំរដ្ឋមន្ដ្រីកសិកម្មនៅ GMS នាថ្ងៃទី១០ សីហា ២០០៧ ក្នុងទីក្រុងប៉េកាំង ។ ពាណិជ្ជកម្មផលិតផលកសិកម្ម ជាពិសេសទាក់ទិននឹងការនាំចេញ បានជួយពង្រឹងតួនាទីកសិកម្មក្នុងការងារអភិវឌ្ឍន៏ ។ រឿងនេះ ពិតជាក់ស្ដែងខ្លាំងណាស់សំរាប់ ប្រទេសដែលគ្រប់គ្រងពាណិជ្ជកម្មដោយផ្ដោតលើកំណើនផ្អែកលើចំនួនការងារ ។

ពាណិជ្ជកម្មចាំបាច់បំផុតសំរាប់ការអភិវឌ្ឍន៏កសិកម្ម និងការកាត់បន្ថយភាពក្រីក្រ ហើយយុទ្ធសាស្ដ្រពាណិជ្ជកម្មកសិកម្ម ក៏មានច្រើនយ៉ាងដែរ អាស្រ័យលើភាពសំបូរធនធាន ប្រវត្តិសាស្ដ្រ សន្តិសុខស្បៀង ប្រភពចំណូលរដ្ឋាភិបាល ជញ្ជីងទូទាត់ និងសមត្ថភាពទំនិញជ្រៀតចូលទៅទីផ្សារផ្សេងៗ ។ល។ នាពេលសព្វថ្ងៃ ពាណិជ្ជកម្មកសិកម្មនៃប្រទេសកំពុងអភិវឌ្ឍន៏ភាគច្រើនបានជួបឧបសគ្គ ។ បញ្ហារារាំងចំបងបំផុតដល់ការធ្វើពាណិជ្ជកម្មកសិកម្មជាមួយប្រទេសអភិវឌ្ឍន៏ដូចជា ជប៉ុន អឺរ៉ុប និងអាមេរិក អាចបែងចែកបានជាបីប្រភេទៈ (១) នៅឆ្ងាយពីទីផ្សារនិងហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្មទន់ខ្សោយ (២) ពន្ធគយនិងរបាំងមិនមែនពន្ធគយ និងវិធានការការពារផ្សេងៗ (៣) តំរូវការពីក្រៅប្រទេសមានកំរិត និងអស្ថិរភាពទីផ្សារ ។

*នៅឆ្ងាយពីទីផ្សារ និងហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្មទន់ខ្សោយៈ* ប្រទេស GMS នៅឆ្ងាយពីទីផ្សារសក្ដានុពល ដែលស្ថិតក្នុងបណ្ដាប្រទេសអភិវឌ្ឍន៏ ។ ការដឹកជញ្ជូនផ្លូវឆ្ងាយត្រូវចំណាយច្រើន ដែលកាត់បន្ថយសមត្ថភាពប្រកួតប្រជែងរបស់ទំនិញ ។ម្យ៉ាងទៀត ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសតិចតួចក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្ម គួបផ្សំនឹងបរិមាណនាំចេញតិចពីប្រទេស GMS នីមួយៗ ធ្វើឱ្យចំណាយលក់ដូរទំនិញមួយមុខៗបែបនេះ ឡើងខ្ពស់ជាងចំណាយក្នុងការនាំចេញទំនិញដុំ ។ ម្យ៉ាងទៀត ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ និងបទប្បញ្ញត្តិគ្មានប្រសិទ្ធភាព ក៏អាចបង្កើនចំណាយដឹកជញ្ជូនដែរ ។ ក្នុងស្ថានភាពបែបនេះ ការជួញជិតៗ មានទាំងជំនួញជាមួយបណ្ដាប្រទេស GMS ផង វាផ្ដល់ផលប្រយោជន៏ច្រើនជាងការជួញទៅឆ្ងាយៗ ។

*ពន្ធគយ របាំងមិនមែនពន្ធគយ និងវិធានការការពារផ្សេងៗៈ* គោលនយោបាយពាណិជ្ជកម្មដ៏សាមញ្ញបំផុតគឺ ការយកពន្ធលើទំនិញនាំចូល (ពន្ធគយ) ។ពន្ធគយ ជាគោលនយោបាយដ៏យូរលង់បំផុតមួយ ដែលបានប្រើប្រាស់តាំងពីដើមរៀងមកសំរាប់ធ្វើជាប្រភពចំណូលរដ្ឋ និងជាមធ្យោបាយបង្កើនតំលៃទំនិញនាំចូល ដើម្បីការពារថ្លៃផលិតផលនៅក្នុងស្រុក ។ បណ្ដាប្រទេសអភិវឌ្ឍន៏ ដូចជា ជប៉ុន អឺរ៉ុប និងសហរដ្ឋអាមេរិក នៅតែយកពន្ធគយខ្ពស់លើផលិតផលកសិកម្ម ។ ជាបន្ថែមលើឧបត្ថម្ភធនដែលរដ្ឋាភិបាលប្រទេសអភិវឌ្ឍន៏ផ្ដល់ឱ្យកសិកររបស់ខ្លួន រដ្ឋក៏បានប្រើប្រាស់របាំងមិនមែនពន្ធគយ និងវិធានការការពារផ្សេងៗ ដើម្បីកាត់បន្ថយការនាំចូលកសិផលមានតំលៃថោកពីប្រទេសកំពុងអភិវឌ្ឍន៏ដែរ ។ ដូច្នេះការប្រឹងប្រែងជំរុញទីផ្សារកសិកម្មក្នុងតំបន់ (បណ្ដាប្រទេស GMS) គឺជាយុទ្ធសាស្ដ្រដ៏ល្អមួយដើម្បីអភិវឌ្ឍកសិកម្មក្នុងប្រទេសទាំងនេះ ។

*តំរូវការពីក្រៅប្រទេសមានកំរិត និងអស្ថិរភាពទីផ្សារៈ* ជាទូទៅ ថ្លៃទំនិញមូលដ្ឋាន មិនកើនថែមទេ នៅពេលចំណូលក្នុងមនុស្សម្នាក់កើនឡើង ។ ការនាំចេញបន្ថែម អាចធ្វើអោយថ្លៃនៅទីផ្សារពិភពលោកធ្លាក់ចុះ សំរាប់ផលិតផលដែលមានតំរូវការស្ទឹក មិនសូវកើនឡើង ។ ដូច្នេះប្រទេសកំពុងអភិវឌ្ឍន៏ក៏ព្រួយបារម្ភថា ផលិតផលមូលដ្ឋានដែលខ្លួនខំផលិត វាមានតំរូវការស្ទឹកនៅប្រទេសអភិវឌ្ឍន៏ ។ ម្យ៉ាងទៀត តាមការពិនិត្យឃើញជាក់ស្ដែងប្រទេសអភិវឌ្ឍន៏តែងខំការពារផលិតផលមូលដ្ឋានរបស់ខ្លួន ជាងផលិតផលឧស្សាហកម្មទៅទៀត ។ ពួកគេតែងជួយទ្រទ្រង់ថ្លៃនៅកសិដ្ឋានឱ្យវានៅខ្ពស់ជាងកំរិតថ្លៃលំនឹងនៅទីផ្សារ ដើម្បីជួយទ្រទ្រង់ដល់ ចំណូលកសិដ្ឋាន ហើយជាទូទៅវានាំឱ្យមានការដាក់កំហិតតឹងរឹងលើទំនិញនាំចូល ។ រីឯប្រទេសកំពុងអភិវឌ្ឍន៏វិញ ពួកគេច្រើនតែរើសអើងចំពោះកសិកម្ម ដែលធ្វើឱ្យថ្លៃនៅកសិដ្ឋានឡើងចុះជាខ្លាំង និងនាំឱ្យការផ្គត់ផ្គង់ផលិតផលគ្មានស្ថិរភាព ។

ដោយសារកំហិតនានាខាងលើ ហើយការចរចានៅអង្គការពាណិជ្ជកម្មពិភពលោក (WTO) ស្ដីពីសាកលភាវូបនីយកម្មពាណិជ្ជកម្មកសិកម្ម ក៏មិនទាន់បានទទួលជោគជ័យ បណ្ដាប្រទេសមហាអនុតំបន់មេគង្គ (GMS) គួរពិចារណាជំរុញពាណិជ្ជកម្មក្នុងតំបន់ ជាជាងផ្ដោតលើទីផ្សារក្នុងប្រទេសអភិវឌ្ឍន៏ ។ នៅពេលហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅ GMS កំពុងត្រូវបានកែលំអ ប្រទេសនីមួយៗគួរយកចិត្តទុកដាក់ និងស្វែងរកជំនាញឯកទេសក្នុងការផលិតដំណាំណាដែលពួកគេ មានឧត្ដមភាពខ្ពស់បំផុតខាងថ្លៃដើម ហើយធ្វើការនាំចូលផលិតផលឯទៀតដែលពួកគេមិនអាចផលិតវាក្នុងតំលៃថោកបាន ។ ក្នុងពេលជាមួយគ្នា ប្រទេសនៅ GMS ទាំងអស់គួរធ្វើការរួមគ្នាក្នុងលក្ខណៈជាអង្គភាពតំបន់មួយ ដើម្បីធ្វើឱ្យកសិកម្មកាន់តែមានសមត្ថភាពប្រកួតប្រជែង និងអាចនាំចេញទៅតំបន់ផ្សេងៗទៀត ។

*ទស្សនវិស័យអភិវឌ្ឍន៍លើផលិតផលកសិកម្មមួយចំនួននៅកម្ពុជា*

ច្រកផ្លូវឆ្លងពីប្រទេសមួយទៅប្រទេសមួយ កំពុងត្រូវបានអភិវឌ្ឍន៍នៅក្នុង GMS ។ ក្នុងបញ្ហាបើកចំហច្រកព្រំដែន ប្រទេសនៅ GMS បានបោះជំហានធំៗទៅមុខ ដោយបានព្រមព្រៀងគ្នាលើវិធានការសំរបសំរួលពាណិជ្ជកម្មជាច្រើន ដូចជាការត្រួតពិនិត្យធ្វើតែមួយលើកនៅច្រកព្រំដែនសំខាន់ៗជាដើម ។ កម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀងមួយជាមួយថៃ ដើម្បីសំរបសំរួលការឆ្លងកាត់ព្រំដែន ដោយចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៦ នៅច្រកប៉ោយប៉ែត-អរញ្ញ ។ កម្ពុជា និងវៀតណាម ក៏បានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀងមួយស្រដៀងគ្នា សំរាប់ច្រកបាវិត-ម៉ុកបៃ នៅពាក់កណ្តាលឆ្នាំ២០០៦ ។

កិច្ចព្រមព្រៀងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន GMS ដែលចាប់អនុវត្តនៅខែវិច្ឆិកា ១៩៩៩ ពីដំបូងជាកិច្ចព្រមព្រៀងត្រីភាគីរវាងឡាវ ថៃ និងវៀតណាម ហើយក្រោយមកចូលរួមដោយកម្ពុជានៅឆ្នាំ២០០១ ចិននៅឆ្នាំ២០០២ និងភូមា នៅឆ្នាំ២០០៣ ។ កិច្ចព្រមព្រៀងនេះ មានគោលដៅសំរបសំរួលចលនាទំនិញ និងប្រជាជនឆ្លងកាត់ព្រំដែន ដោយផ្តោតលើការត្រួតពិនិត្យតែមួយលើក និងបែបបទទិដ្ឋាការយ៉ាងសាមញ្ញ ។ ការឆ្លងកាត់ព្រំដែនងាយស្រួលជាងមុន ជាគន្លឹះមួយសំរាប់ទាក់ទាញកសិ-ឧស្សាហកម្មថៃ និងវៀតណាម ឱ្យមកធ្វើវិនិយោគកសិកម្មនៅកម្ពុជា ។ វិនិយោគិនមានការចាប់អារម្មណ៍លើផលិតផលពីរមុខគឺ កៅស៊ូ និងដំឡូងមី ដែលត្រូវបានដាំដុះនៅកម្ពុជា ហើយនាំចេញទៅថៃ និងវៀតណាម បន្ទាប់មកនាំចេញបន្តទៅចិន ក្រោយពេលបានកែច្នៃ និងវេចខ្ចប់ ។ ការនាំចូលគោក្របីក្រៅផ្លូវការពីថៃមកកម្ពុជាសំរាប់ការប្រើប្រាស់ក្នុងស្រុក រួចហើយនាំចេញបន្តទៅវៀតណាម គេបានពិនិត្យឃើញតាំងពីមុនពេលកម្ពុជា បានចុះអនុស្សារណៈព្រមព្រៀងជាមួយប្រទេសទាំងពីរទៅទៀត ។ McNaughton (2004) បានប៉ាន់ស្មានថាការនាំចេញគោក្របីរស់ពីកម្ពុជាទៅវៀតណាម ថៃ និងម៉ាឡេស៊ី នៅឆ្នាំ១៩៩២ មានចំនួនជាក់ស្តែងច្រើនជាងតួលេខរាយការណ៍ដប់ដង ។ ក្រោយឆ្នាំ២០០៥ ចលនាឆ្លងកាត់ព្រំដែនក្រៅផ្លូវការបានថយចុះ ដែលប្រហែលមកពីមានការសំរបសំរួលខាងពាណិជ្ជកម្ម ។

ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្មនៅ GMS នាថ្ងៃទី១០ សីហា ២០០៧ នៅក្រុងប៉េកាំង រដ្ឋមន្ត្រីទាំងអស់បានបញ្ជាក់អះអាងសាជាថ្មីពីសារៈសំខាន់នៃកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ ពីព្រោះប្រជាជនរាប់លាននាក់ដែលរស់នៅតាមជនបទ មានជីវភាពពឹងផ្អែកលើកសិកម្ម ។ រដ្ឋមន្ត្រីបានប្តេជ្ញាបន្តការគាំទ្រដល់ការងាររបស់ក្រុមការងារកសិកម្ម (WGA) នៅ GMS ។ ការងារកសិកម្មដែលអនុវត្តក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ GMSហាក់ដូចមានប្រសិទ្ធភាពល្អ ក្នុងការជំរុញកំណើនពាណិជ្ជកម្ម និងការផ្លាស់ប្តូរបច្ចេកទេសកសិកម្ម ។ ឧ. អ្នកបច្ចេកទេសកសិកម្មកម្ពុជាជាច្រើននាក់ បានទទួលការបណ្តុះបណ្តាលនៅ ចិន ថៃ និងវៀតណាមស្តីពីវារីវប្បកម្ម ការចិញ្ចឹមសត្វ ការត្រួតពិនិត្យ និងទប់ស្កាត់ជំងឺសត្វឆ្លងកាត់ព្រំដែន និងការប្រើប្រាស់ដី ។ ចិនដែលមានបច្ចេកទេសកសិកម្មជឿនលឿនជាងគេ បានយល់ព្រមផ្តល់ការបណ្តុះបណ្តាលលើការងារអនុវត្តន៍ជាក់ស្តែងខាងកសិកម្ម ដល់បណ្តាប្រទេសនៅ GMS ។ ទោះបីកម្ពុជា ត្រូវប្រឈមមុខនឹងកំហិតមួយចំនួននៅក្នុងកម្មវិធីអភិវឌ្ឍន៍កសិកម្មនៅ GMS ដោយសារមានការប្រកួតប្រជែងខ្លាំងក្នុងផលិតផលប្រភេទខ្លះពីសំណាក់ប្រទេសមានកំរិតអភិវឌ្ឍន៍ខ្ពស់ជាង ជាពិសេស ថៃ និងវៀតណាម ប៉ុន្តែគេនៅតែអាចជំរុញការអភិវឌ្ឍន៍កសិកម្មបានតាមរយៈការកសាងសមត្ថភាព និងការផ្តល់ឱកាសសំរាប់នាំចេញ ។ ផលិតផលកសិកម្មចំបងៗមួយចំនួននៅកម្ពុជា (ឧ. ដំឡូងមី និងកៅស៊ូ) នៅតែមានអនាគតភ្លឺស្វាង ប៉ុន្តែផលិតផលមួយចំនួនទៀតត្រូវពឹងផ្អែកលើការកែលំអសមត្ថភាពប្រកួតប្រជែងរបស់វា ។

## សន្និដ្ឋាន

ពាណិជ្ជកម្មមិនមែនជាឱសថទិព្វសំរាប់ការអភិវឌ្ឍន៍ទេ ប៉ុន្តែបើគ្មានវាការអភិវឌ្ឍន៍មិនអាចដំណើរការបានប្រសើរឡើយ ។ យើងយល់ស្របថា "គ្មានការជួញដូរ គឺគ្មានការអភិវឌ្ឍន៍" ប៉ុន្តែកម្ពុជាត្រូវតែកែលំអសមត្ថភាពប្រកួតប្រជែងរបស់ខ្លួនតាមរយៈការពង្រីក និងឯកទេសនីយកម្មផលិតកម្ម ។

លក្ខខណ្ឌចាំបាច់សំរាប់ពាណិជ្ជកម្ម គឺផលិតផលមានលក្ខណៈប្រកួតប្រជែង ។ ប៉ុន្តែលក្ខខណ្ឌនេះគ្មានប្រយោជន៍អ្វីទេ បើសិនចំណាយដឹកជញ្ជូនវាខ្ពស់ជាងគំលាតរវាងថ្លៃទំនិញនៅប្រទេសនាំចូល និងថ្លៃទំនិញនោះនៅប្រទេសនាំចេញ ។ ចំណាយខ្ពស់លើការដឹកជញ្ជូន វាប៉ះពាល់ពាណិជ្ជកម្មគ្រប់ប្រភេទ ។ នៅពេលប្រទេសមួយមានសមត្ថភាពផលិតប្រកួតប្រជែង និងមានចំណាយដឹកជញ្ជូនទាបហើយ គេត្រូវតែជ្រៀតចូលទីផ្សារអន្តរជាតិឱ្យបាន ។

សំរាប់ការអភិវឌ្ឍន៍កសិកម្មកម្ពុជា គឺមានផលិតផលមួយចំនួនដែលមានសក្តានុពលសំរាប់ការនាំចេញ ដូចជា ដំឡូងមី កៅស៊ូ អង្ករ ជាដើម ។ គេអាចឃើញនូវឱកាសច្រើនទៀតសំរាប់នាំចេញផលិតផលទាំងនោះ បើសិនមានការកែលំអផលិតភាព និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ។ កំណើនទីផ្សារនៅ GMS ជាកត្តាជំរុញដល់ការជួញដូរផលិតផលបែបនេះ ។ នៅពេលមានទីផ្សារក្នុងតំបន់ហើយ កម្ពុជាគួរពិចារណាកាត់បន្ថយចំណាយប្រតិបត្តិការ និងចំណាយដឹកជញ្ជូន ហើយគួបផ្សំនឹងការកែលំអផលិតភាព វានឹងជួយបង្កើនពាណិជ្ជកម្មកសិកម្ម និងប្រាក់ចំណូលរបស់ប្រជាជនដែលរស់នៅអាស្រ័យដោយកសិកម្ម ។

## កំណត់សំគាល់

១. ទ្រឹស្តីបែបក្លាស៊ិកនៃការរីកលូតលាស់ បានមើលរំលងយ៉ាងយូរនូវឥទ្ធិពលទាំងនេះ ។

២. ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានជួយដល់ GMS តាំងពីពេលគិតគូរបង្កើតតំបន់នេះឡើងនៅឆ្នាំ១៩៩២ ។

## ឯកសារយោង


Krugman, Paul R. & Maurice Obstfeld (2003), International Economics: Theory and Policy, Sixth Edition (New York: Harper Collins Publishers)

Martin, Will & Kym Anderson (2006), Agricultural trade reform and the Doha development agenda (Washington, DC: World Bank).

McNaughton, Andrew (2004), Animal Production System (in Cambodia) in the Political Economy of Pro-Poor Livestock Policy in Cambodia, Sophal Ear and David K. Leonard, eds., University of California, Berkeley

Norton, George W. & Jeffrey Alwang (1993), Introduction to Economics of Agricultural Development (McGraw-Hill)

Riddell, Tom, Jean Shackelford, Steve Stamos & Geoffrey Schneider (2002), Economics: a tool for critically undertanding society, 6th ed. (Addison Wesley)